ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្ដីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែតុលា ឆ្នាំ២០២២

នៅក្នុងខែតុលា ឆ្នាំ២០២២នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ៖

## ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១-សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា

-បានបំពេញភារកិច្ចជាប្រមុខរដ្ឋស្ដីទី ចាប់ពីថ្ងៃទី២១ ខែសីហា ឆ្នាំ២០២២ ដល់ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២។

### ១.១.១-សកម្មភាពចូលរួមកិច្ចប្រជុំ

-បានដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន០២លើក និងប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៤ ចំនួន១លើក។

### ១.១.២-កិច្ចសហប្រតិបត្តិការ និងបដិសណ្ឋារកិច្ចនៅថ្នាក់ជាតិ-អន្តរជាតិ

-បានអញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ទៅបំពេញទស្សនកិច្ចជាផ្លូវការ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម។

-បានអនុញ្ញាតឱ្យឯកឧត្ដមបណ្ឌិត **ចូហ្សេ រ៉ាម៉ូស ហរតា** (Jose Ramos-Horta) ប្រធានាធិបតី នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ ចូលជួបសម្ដែងការគួរសម និងសវនាការ នៅវិមានព្រឹទ្ធសភា។

-បានអនុញ្ញាតឱ្យឯកឧត្ដម Manuel Marrero Cruz នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋគុយបា ចូលជួបសម្ដែងការគួរសម និងសវនាការ ក្នុងឱកាសដែលឯកឧត្ដម ដឹកនាំគណៈប្រតិភូអញ្ជើញមកបំពេញទស្សនកិច្ចជាផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា។

### ១.១.៣-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញចូលរួមប្រារព្ធព្រះរាជពិធីថ្វាយឧទ្ទិសព្រះរាជកុសលព្រះវិញ្ញាណក្ខន្ធ



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

**ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ** ជាទីគោរពសក្ការៈ ដ៏ខ្ពង់ខ្ពស់បំផុត ក្នុងព្រះរាជពិធីបុណ្យខួប១០០ព្រះវស្សា នៃការយាងប្រសូត ថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩២២ និងព្រះរាជពិធីបុណ្យគម្រប់ខួប១០ព្រះវស្សា នៃការយាងសោយព្រះទិវង្គត ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ នៅបរិវេណព្រះឧបោសថរតនារាមព្រះវិហារព្រះកែវមរកត ក្នុងព្រះបរមរាជវាំង។

-បានអញ្ជើញទទួលព្រះរាជដំណើរ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ស្តេចយាងនិវត្តន៍ពីទីក្រុងប៉េកាំង នៃសាធារណរដ្ឋ-ប្រជាមានិតចិន នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។

-បានអញ្ជើញគោរពវិញ្ញាណក្ខន្ធព្រឹទ្ធមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **ទន់ ធី** ដែលត្រូវជាម្តាយក្មេកឯកឧត្តម**យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងជាប្រធានគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ ស្ថិតនៅភូមិពន្លៃ ឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។

-បានអញ្ជើញចូលរួមពិធីលៀងសាយភោជន៍ផ្លូវរដ្ឋ ស្វាគមន៍ជូនចំពោះដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់ឯកឧត្តមបណ្ឌិត **ចូហ្សេ រ៉ាម៉ូស ហរតា** (Jose Ramos-Horta) ប្រធានាធិបតី នៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ និងគណៈប្រតិភូ ក្រោមព្រះរាជាអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះបរមរាជវាំង។

**១.១.៤-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៦ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៨ច្បាប់។

**១.២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ឹម កា អនុប្រធានទី១ ព្រឹទ្ធសភា**

-បានទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភា ចាប់ពីថ្ងៃទី២១ ខែសីហា ឆ្នាំ២០២២ ដល់ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២២។

### ១.២.១-សកម្មភាពចូលរួមកិច្ចប្រជុំ

-បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ចំនួន០២លើក និងប្រជុំពេញអង្គ ព្រឹទ្ធសភា នីតិកាលទី៤ ចំនួន១លើក។

### ១.២.២-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញជូន និងទទួលដំណើរសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភាបំពេញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។

-បានអញ្ជើញចូលរួមកម្មវិធីសូត្រមន្តបុណ្យកឋិនទានសាមគ្គី ស្ថិតនៅសាលាខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ។

### ១.២.៣-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន០៨ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៤៨ច្បាប់។

## ១.៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា

### ១.៣.១-សកម្មភាពចូលរួមកិច្ចប្រជុំ

-បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ចំនួន០២លើក និងប្រជុំពេញអង្គ ព្រឹទ្ធសភា នីតិកាលទី៤ ចំនួន១លើក។

### ១.៣.២-សកម្មភាពចុះមូលដ្ឋាន

-បានអនុញ្ញាឱ្យក្រុមការងារដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅក្នុងឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល។

### ១.៣.៣-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាថ្វាយកម្រងផ្កា និងគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ** នៅមណ្ឌបតម្កល់ព្រះបរមរូប រាជធានីភ្នំពេញ។

-បានអញ្ជើញជូន និងទទួលដំណើរសម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា បំពេញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។

-បានអញ្ជើញធ្វើបទឧទ្ទេសនាម ក្រោមប្រធានបទ " **ភាពជាអ្នកដឹកនាំ** " ជូនដល់សិក្ខាកាមដែលជាអភិបាលរងរាជធានីខេត្តទាំង២៥ ដែលទើបទទួលបានការតែងតាំងថ្មី នៅទីស្តីការក្រសួងមហាផ្ទៃ។

-បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសពព្រឹទ្ធមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **ទន់ ធី** ម្តាយក្មេករបស់ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្ម និងជនបទ និងជាប្រធានគណៈកម្មាធិការជាតិជំរុញចលនា ភូមិមួយផលិតផលមួយ ស្ថិតនៅភូមិពន្លៃ ឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ។

**១.៣.៤-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៦ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១២ច្បាប់។

## ២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

ព្រឹទ្ធសភាបានបើកកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ដើម្បីពិនិត្យ និងសម្រេចលើសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារទីបួន ស្តីពីវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន។

## ៣.សម័យប្រជុំពេញអង្គព្រឹទ្ធសភា

ព្រឹទ្ធសភាបានបើកសម័យប្រជុំលើកទី៩ នីតិកាលទី៤ ចំនួន០១លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើពិធីសារ ទីបួន ស្តីពីវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន។

## ៤.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

សមាជិកព្រឹទ្ធសភា បានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ៤.១ មុខងារនីតិកម្ម

-បានអញ្ជើញប្រជុំអន្តរគណៈកម្មការជាមួយតំណាងរាជរដ្ឋាភិបាល ដឹកនាំដោយឯកឧត្តម **ជិន ប៊ុនសាន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ ស្តីពីវិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន នៅវិមានព្រឹទ្ធសភា។

-បានអញ្ជើញចូលរួមប្រជុំជាមួយតំណាងជនជាតិដើមភាគតិចចំនួន១៦អំបូរជនជាតិពាក់ព័ន្ធនឹងការស្នើសុំផ្តល់ធាតុចំនួន៨ ចូលក្នុងសេចក្តីព្រាងវិសោធនកម្មច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ ឆ្នាំ២០០៨ និងច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២ ក្រោមអធិបតីភាពឯកឧត្តម **យ៉ង់ សែម** ប្រធានគណៈកម្មការទី១ ព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា ។

### ៤.២ មុខងារតាមដានការអនុវត្តច្បាប់

-បានអញ្ជើញជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **ខៀវ កាញារីទ្ធ** មន្ត្រីក្រសួងព័ត៌មាន ដើម្បីឈ្វេងយល់អំពីលទ្ធផលការងារសម្រេចបានរបស់ក្រសួងព័ត៌មានក្នុងឆ្នាំ២០២១ និងទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០២២, ការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងការកសាងសេចក្តីព្រាងច្បាប់ ស្តីពីសិទ្ធទទួលបានព័ត៌មាន។

-បានអញ្ជើញជួបពិភាក្សា និងផ្លាស់ប្តូរបទពិសោធន៍ការងារជាមួយថ្នាក់ដឹកនាំលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) តំណាងមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន នៅវិមានព្រឹទ្ធសភា។

-បានអញ្ជើញប្រជុំ ដើម្បីត្រៀមជួបសវនាការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងការជួញដូរ និងក្រសួងកិច្ចនារី ព្រមទាំងគម្រោងរៀបចំអបអរសាទរទិវាសិទ្ធិមនុស្សអន្តរជាតិ១០ធ្នូ ឆ្នាំ២០២២ នៅសាលប្រជុំព្រឹទ្ធសភា។

### ៤.៣ មុខងារតំណាង

-បានទទួលពាក្យបណ្តឹងចំនួន០៩ករណី បញ្ជូនពាក្យបណ្តឹងទៅក្រសួង រាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន០៣ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធចំនួន០១ករណី កំពុងពិនិត្យសិក្សាចំនួន០៧ករណី។

-បានអញ្ជើញចូលរួមវេទិកាពិគ្រោះយោបល់ ស្តីពីតម្រូវការសេវាសង្គមរបស់ គ.ក.ស.ក នៃក្រុមប្រឹក្សារាជធានីភ្នំពេញ អាណត្តិទី៣ និងការសួរសុខទុក្ខចាស់ជរា

អបអរសាទរទិវាមនុស្សចាស់កម្ពុជា និងមនុស្សចាស់អន្តរជាតិ ០១តុលា នៅរាជធានីភ្នំពេញ។

-បានអញ្ជើញជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំខេត្ត និងយុវជនតាមបណ្តាស្រុក ក្រុង ដើម្បីផ្តល់បទពិសោធន៍ល្អៗ និងជាគ្រឹះដើម្បីយកទៅបណ្តុះបណ្តាលដល់យុវជនបន្តវេននៅថ្ងៃខាងមុខ និងបានជួបពិភាក្សាការងារជាមួយប្រធានមន្ទីរសុខាភិបាលខេត្តពោធិ៍សាត់ ក្នុងការត្រៀមផ្តល់ជូនថ្នាំពេទ្យជូនប្រជាពលរដ្ឋក្រីក្រ ដែលជាអំណោយរបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា។

-បានអញ្ជើញជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ ស្តីពីតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ និងការផ្តល់សេវាធារណៈជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន ស្ថិតនៅក្នុងស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

-បានអញ្ជើញចូលរួមប្រជុំក្រុមសមាជិកាព្រឹទ្ធសភា ដើម្បីពិភាក្សាត្រៀមរៀបចំវេទិកាស្តីពីការពង្រឹងសមត្ថភាពដឹកនាំ ក្នុងការផ្តល់សេវាសាធារណៈរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី នៅខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងខេត្តប៉ៃលិន។

-បានអញ្ជើញចូលរួមសន្និសីទ ស្តីពីការរម្លឹកខួប១០០ឆ្នាំ នៃថ្ងៃប្រសូតរបស់ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរ ព្រះបរមរតនកោដ្ឋ នៅវិទ្យាស្ថានបារាំងប្រចាំកម្ពុជា។

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបើកអង្គសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០២២ លើប្រធានបទ " ការស្តារឡើងវិញនៃប្រទេសកម្ពុជា៖ ការអភិវឌ្ឍប្រកបដោយនិរន្តរភាពបន្ទាប់ពីជំងឺកូវីដ-១៩ " ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសុខាភ្នំពេញ។

-បានអញ្ជើញចូលរួមសិក្ខាសាលា ស្តីពី " តួនាទីសភាក្នុងការប្រែប្រួលអាកាសធាតុ " រៀបចំដោយគណៈកម្មការទី៣ រដ្ឋសភា សហការជាមួយក្រសួងបរិស្ថាន ក្រោមការជួយឧបត្ថម្ភគាំទ្រពីគម្រោងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំនៅកម្ពុជា(UNDP) នៅវិមានរដ្ឋសភា។

-បានអញ្ជើញជាអធិបតីក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៣ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីមកពីខណ្ឌចំនួន០៧ រួមមាន៖ ខណ្ឌដង្កោ ខណ្ឌមានជ័យ ខណ្ឌទួលគោក ខណ្ឌព្រែកព្នៅ ខណ្ឌបឹង

កេងកង ខណ្ឌពោធិ៍សែនជ័យ និងខណ្ឌជ្រោយចង្វារ សរុបចំនួន២៨៦នាក់ នៅរាជធានីភ្នំពេញ។

-បានអញ្ជើញចូលរួមជាវាគ្មិនក្នុងវេទិកា ស្តីពី " យុទ្ធនាការនារីវ័យក្មេងឆ្ពោះទៅភាពជាអ្នកដឹកនាំ (Girl to Leader)" ក្រោមអធិបតីភាពលោកជំទាវ **ឡោក ខេង** ប្រធានគណៈកម្មការទី៨ នៃរដ្ឋសភា។

-បានអញ្ជើញជាវាគ្មិនក្នុងសិក្ខាសាលាប្រវត្តិសាស្ត្រយោធា ស្តីពីការរៀបចំពិនិត្យខ្លឹមសារអនុវត្តនយោបាយ ឈ្នះ ឈ្នះ ក្នុងទិសយោធភូមិភាគទី៥ នៅសាលប្រជុំទីបញ្ជាការយោធភូមិភាគទី៥ ខេត្តបាត់ដំបង។

-បានអញ្ជើញធ្វើបទបង្ហាញអំពីតួនាទី ភារកិច្ចរបស់ព្រឹទ្ធសភាជូនដល់សាស្ត្រាចារ្យ និងនិស្សិតពូកែមកពីសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ខេត្តបាត់ដំបង នៅសាលសិក្ខាសាលាខាងជើងព្រឹទ្ធសភា។

-បានអញ្ជើញចូលរួមកិច្ចប្រជុំកំពូលស្ត្រីអាស៊ានលើកទី២ " ការកសាងអនាគតប្រកបដោយចីរភាព បរិយាប័ន្ន និងកាន់តែរឹងមាំ៖ បំផុសសហគ្រិនភាពរបស់ស្ត្រីក្នុងអាស៊ាន " ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានសន្តិភាព។

-បានអញ្ជើញនាំយកកូនឈើប្រណិតចំនួន៧៨,៦៩០ដើម ដើម្បីចូលរួមចំណែកក្នុងការដាំដើមឈើនៅតំបន់រមណីយដ្ឋានភ្នំតាម៉ៅ ខេត្តតាកែវ។

-បានអញ្ជើញចូលរួមថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដឹកនាំដោយឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ព្រឹទ្ធសភា នៅមណ្ឌបតម្កល់ព្រះបរមរូប រាជធានីភ្នំពេញ។

-បានអញ្ជើញជាគណៈអធិបតី និងចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗចំនួន៩៧លើក។

-ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភាបានអញ្ជើញចុះជួបសំណេះសំណាលសាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំអាណត្តិទី៥ នៅមូលដ្ឋាន

ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខសណ្តាប់ធ្នាប់ ការផ្តល់សេវាសាធា-រណៈជូនប្រជាពលរដ្ឋ និងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ពិនិត្យហេដ្ឋារចនា-សម្ព័ន្ធ សម្ពោធសមិទ្ធផលនានា ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយទឹកជំនន់ទឹកភ្លៀង និងបញ្ហាប្រឈមនានា ជាពិសេស បានអំពាវនាវឱ្យប្រជាពលរដ្ឋអញ្ជើញទៅពិនិត្យ និងចុះឈ្មោះបោះឆ្នោតឱ្យបានគ្រប់ៗគ្នា នៅតាមមូលដ្ឋានរៀងៗខ្លួន ក្នុងភូមិភាគទាំង៨ ចំនួន១១១លើក។

## ៤.៤ កិច្ចសហប្រតិបត្តិការអន្តរជាតិ

ការងារសហប្រតិបត្តិការអន្តរជាតិរបស់ព្រឹទ្ធសភា ជាពិសេស ទំនាក់ទំនងក្នុងកម្រិតតំបន់ និងអន្តរជាតិ សមាជិក សមាជិកាព្រឹទ្ធសភា បានចូលរួមយ៉ាងសកម្ម និងទទួលបានលទ្ធផលជាវិជ្ជមានដូចខាងក្រោម៖

-បានអញ្ជើញចូលរួមមហាសន្និបាតសហភាពអន្តរសភា លើកទី១៤៥ (IPU-145) និងកិច្ចប្រជុំពាក់ព័ន្ធនានា នៅទីក្រុងKigali នៃសាធារណរដ្ឋRwanda។

-បានអញ្ជើញចូលរួមកិច្ចប្រជុំប្រចាំឆ្នាំនៃវេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិក លើកទី៣០ (APPF-30th) នៅទីក្រុងបាងកក ព្រះរាជាណាចក្រថៃឡង់ដ៍។

-បានអញ្ជើញទៅទស្សនកិច្ចនៅសមាគមសណ្តែកសៀងអាមេរិក និងចូលរួមកម្មវិធីពានរង្វាន់ស្បៀងអាហារពិភពលោក នៅរដ្ឋIOWA សហរដ្ឋអាមេរិក។

-បានអញ្ជើញចូលរួមប្រជុំ ដើម្បីត្រៀមចូលរួមកិច្ចប្រជុំក្រុមការងារទទួលបន្ទុកការសើរើលក្ខន្តិកៈ APF, មហាសន្និបាតប្រចាំឆ្នាំនៃបណ្តាញក្រុមសីលធម៌សមាជិកព្រឹទ្ធសភាប្រើភាសាបារាំង នៅសាធារណរដ្ឋបារាំង និងបំពេញទស្សនកិច្ចការងារនៅសភាសហ-ព័ន្ធវាឡូនីប្រ៊ុចសែល នៃព្រះរាជាណាចក្របែលហ្ស៊ិក។

-បានអញ្ជើញចូលរួមប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងកម្មវិធីទស្សនកិច្ចផ្លូវការរបស់គណៈប្រតិភូព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នៅសាធារណរដ្ឋសង្គមនិយមវៀតណាម

-បានអញ្ជើញដឹកនាំកិច្ចប្រជុំ នៃគណៈកម្មាធិការរៀបចំនៃមហាសន្និបាតអន្តរសភាអាស៊ានអាយប៉ា លើកទី៤៣ (Committee on Organization Matters AIPA-43) ដើម្បីពិនិត្យអំពីវឌ្ឍនភាពការងាររបស់គណៈកម្មាធិការ និងបញ្ហាផ្សេងៗ នៅវិមានព្រឹទ្ធសភា។

-បានអញ្ជើញចូលរួមប្រជុំដើម្បីពិនិត្យខ្លឹមសារសេចក្តីសម្រេច និងឯកសារទស្សនា

ទាននៃគណៈកម្មការរៀបចំមហាសន្និបាតអន្តរសភាអាស៊ាន (អាយប៉ា AIPA) លើកទី៤៣ នៅវិមានរដ្ឋសភា។

-បានអញ្ជើញទទួលគណៈប្រតិភូសាធារណរដ្ឋកូរ៉េ មកបំពេញទស្សនកិច្ចសិក្សាឈ្វេងយល់អំពីកសិកម្ម កសិឧស្សាហកម្ម ដាំដុះ ចិញ្ចឹម កែច្នៃ និងហេដ្ឋារចនាសម្ព័ន្ធនានានៅតំបន់អភិវឌ្ឍន៍កំពង់ផែឧកញ៉ា ម៉ុង កែវផុស។

ថ្ងៃសុក្រ ១១កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែវិច្ឆិកា ឆ្នាំ២០២២

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**កិត្តិសង្គហបណ្ឌិត ទេព ងន**

<u>ចម្លងជូន</u>

- *ក្រុមប្រឹក្សាធម្មនុញ្ញ*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*
- *ក្រសួងយុត្តិធម៌*
- *ក្រសួងព័ត៌មាន*
- *(ជូនជ្រាបជាព័ត៌មាន)*
- *កាលប្បវត្តិ-ឯកសារ*